**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១៧៣ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតរង្វាន់បុរេប្រទានសម្រាប់ឆ្នាំ២០១៧ របស់សាកលវិទ្យាល័យស្វាយរៀង

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**សាកលវិទ្យាធិការ**
**សាកលវិទ្យាល័យស្វាយរៀង**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែ មេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា.ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧នៃអនុក្រឹត្យ លេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យ ហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការ សាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកា គណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យ- បុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៦២ អយក.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យ អនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១** -

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក ៦០(ការទិញ) ៦១(សេវា) ៦២(អត្ថប្រយោជន៍សង្គម) និង៦៤ (បន្ទុកបុគ្គលិក) នៅសាកលវិទ្យាល័យស្វាយរៀងនៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២** -

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣** -

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤** -

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គ-នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យស្វាយរៀង ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួង សេដ្ឋ-កិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

សាកលវិទ្យាធិការ
សាកលវិទ្យាល័យស្វាយរៀង

ទុំ សារវុធ

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អង្គភាពថវិកាសាកលវិទ្យាល័យស្វាយរៀង

**តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន**

**ថវិកាកម្មវិធីឆ្នាំ២០១៧ របស់អង្គភាពថវិកាសាកលវិទ្យាល័យស្វាយរៀង**

ឯកតាគិតជារៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទានបង្គួបរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥ = ៣/៤ | ៦=៣/២ |
| | | | សរុប | 3,789,500,000 | 2,916,500,000 | 1,002,300,000 | 1,914,200,000 | 250,575,000 | 34.4% |
| 60 | | | ការទិញ | 1,890,700,000 | 1,243,700,000 | 336,200,000 | 907,500,000 | 84,050,000 | 27.0% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 30,000,000 | 30,000,000 | 30,000,000 | - | 7,500,000 | 100.0% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100.0% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 474,200,000 | 103,200,000 | 103,200,000 | - | 25,800,000 | 100.0% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 274,200,000 | 53,200,000 | 53,200,000 | - | 13,300,000 | 100.0% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 200,000,000 | 50,000,000 | 50,000,000 | - | 12,500,000 | 100.0% |
| | 6003 | | ស្បៀងអាហារនិងផលិតផលកសិកម្ម | 49,000,000 | 49,000,000 | 49,000,000 | - | 12,250,000 | 100.0% |
| | | 60031 | ស្បៀង | 3,000,000 | 3,000,000 | 3,000,000 | - | 750,000 | 100.0% |
| | | 60033 | ពូជនិងកូនរុក្ខជាតិ | 16,000,000 | 16,000,000 | 16,000,000 | - | 4,000,000 | 100.0% |
| | | 60034 | ផលិតផលការពារសុខុមាលភាពរុក្ខជាតិ និងជី | 30,000,000 | 30,000,000 | 30,000,000 | - | 7,500,000 | 100.0% |
| | 6005 | | សម្ភារៈតូចតាច សម្លៀកបំពាក់ និងសម្ភារៈបរិក្ខារ | 1,061,500,000 | 1,061,500,000 | 154,000,000 | 907,500,000 | 38,500,000 | 14.5% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 777,500,000 | 777,500,000 | 34,000,000 | 743,500,000 | 8,500,000 | 4.4% |
| | | 60052 | លក្ខារីម | 215,800,000 | 215,800,000 | 51,800,000 | 164,000,000 | 12,950,000 | 24.0% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 68,200,000 | 68,200,000 | 68,200,000 | - | 17,050,000 | 100.0% |
| | 6006 | | ថាមពលនិងទឹក | 276,000,000 | - | - | - | - | #DIV/0! |
| | | 60061 | អគ្គិសនី | 240,000,000 | - | - | - | - | #DIV/0! |
| | | 60062 | ទឹក | 36,000,000 | - | - | - | - | #DIV/0! |
| 61 | | | សេវាកម្ម | 1,625,800,000 | 1,565,800,000 | 559,100,000 | 1,006,700,000 | 139,775,000 | 35.7% |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | 6105 | | ការថែទាំនិងជួសជុល | 1,234,700,000 | 1,174,700,000 | 168,000,000 | 1,006,700,000 | 42,000,000 | 14.3% |
| | | 61051 | ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងវែន | 80,200,000 | 80,200,000 | 16,000,000 | 64,200,000 | 4,000,000 | 20.0% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 977,500,000 | 977,500,000 | 35,000,000 | 942,500,000 | 8,750,000 | 3.6% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 117,000,000 | 57,000,000 | 57,000,000 | - | 14,250,000 | 100.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍ | 60,000,000 | 60,000,000 | 60,000,000 | - | 15,000,000 | 100.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 105,100,000 | 105,100,000 | 105,100,000 | - | 26,275,000 | 100.0% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100.0% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 65,100,000 | 65,100,000 | 65,100,000 | - | 16,275,000 | 100.0% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100.0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 160,000,000 | 160,000,000 | 160,000,000 | - | 40,000,000 | 100.0% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 33,000,000 | 33,000,000 | 33,000,000 | - | 8,250,000 | 100.0% |
| | | 61122 | សោហ៊ុយបេសកកម្ម | 21,000,000 | 21,000,000 | 21,000,000 | - | 5,250,000 | 100.0% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 106,000,000 | 106,000,000 | 106,000,000 | - | 26,500,000 | 100.0% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 64,000,000 | 64,000,000 | 64,000,000 | - | 16,000,000 | 100.0% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 33,000,000 | 33,000,000 | 33,000,000 | - | 8,250,000 | 100.0% |
| | | 61132 | សោហ៊ុយបេសកកម្ម | 12,000,000 | 12,000,000 | 12,000,000 | - | 3,000,000 | 100.0% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 19,000,000 | 19,000,000 | 19,000,000 | - | 4,750,000 | 100.0% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 42,000,000 | 42,000,000 | 42,000,000 | - | 10,500,000 | 100.0% |

| ជំពូក | គណនី | អនុគណនី | ចរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទានបង្គុំបច្ចុប្បន្ន រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ឬ | ៦=៣/២ |
| 64 | | | បន្ទុកបុគ្គលិក | 207,000,000 | 87,000,000 | 87,000,000 | - | 21,750,000 | 100.0% |
| | 6403 | | វង្វាន់និងប្រាក់បំណាច់ផ្សេងៗ | 202,000,000 | 87,000,000 | 87,000,000 | - | 21,750,000 | 100.0% |
| | | 64032 | ប្រាក់បំណាច់សម្រាប់ប្រឡង-ប្រឡងប្រជែង | ...115,000,000 | | | | | #DIV/0! |
| | | 64038 | ប្រាក់បំណាច់ផ្សេងៗ | 87,000,000 | 87,000,000 | 87,000,000 | - | 21,750,000 | 100.0% |
| | 6405 | | ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ | 5,000,000 | - | - | - | - | #DIV/0! |
| | | 64051 | មន្ត្រីមានជំងឺ | 5,000,000 | - | - | - | - | #DIV/0! |
| ប្រភេទទី២ : បន្ទុកហិរញ្ញវត្ថុ | | | | | | | - | - | #DIV/0! |
| 62 | | | អត្ថប្រយោជន៍សង្គម | 66,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100.0% |
| | 6202 | | ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 46,000,000 | - | - | - | - | #DIV/0! |
| | | 62025 | អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុង | 46,000,000 | - | - | - | - | #DIV/0! |
| | 6203 | | ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គមនិង | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100.0% |
| | | 62035 | ឧបត្ថម្ភសហគមន៍កីឡានិងវប្បធម៌ | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100.0% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៥ ខែ មករា ឆ្នាំ២០១៧
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
ម៉ិញ បានសុវណ្ណអានិច្ចាស៊ីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៧
ជ.អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា
គិន_កោសល្ល

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧
ប្រធានការិយាល័យគណនេយ្យ

ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧
រដ្ឋទេយ្យករបុរេប្រទាន

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧
[illegible] សាកលវិទ្យាល័យស្វាយរៀង
ទុំ_សារាវុធ